

# ក្តីស្រមៃរបស់អ្នករចនាលម្អម្នាក់

The Asia Foundation - Let’s Read

Youn Sokhoeut

Let’s Read
The Asia Foundation



អក្ខរា ដើរចូលក្នុងបន្ទប់គេងរបស់នាង និងលោកយាយ រួចប្រះខ្លួនលើគ្រែ។បរិយាកាសរស់នៅក្នុងផ្ទះនេះគួរឲ្យធុញថប់ និងអាប់អួរ។ ពណ៌បន្ទប់ក៏ ស្រអាប់ ហើយគ្មានគ្រឿងសង្ហារិមស្អាតៗទៀត។ អក្ខរា គិតថា "ក្នុងគ្រួសារនេះ គ្មានអ្នកណាម្នាក់ដឹងពីរបៀបធ្វើយ៉ាងណាឲ្យផ្ទះនេះមើលទៅស្រស់ស្អាតដូចខ្ញុំទេ។" នាង ចង់ធ្វើឲ្យផ្ទះនេះស្រស់ស្អាត ប៉ុន្តែឪពុកម្ដាយនាងមិនយល់ព្រមទេ។



លោកយាយ ដើរសំដៅមក អក្ខរា រួចនិយាយថា ″ចៅដឹងទេថា ចៅមិនអាចរុះរើផ្លាស់ប្ដូររបស់អ្នកដទៃបានទេណាចៅ។″ ″ប៉ុន្ដែ ចៅអាចធ្វើឲ្យអ្វីៗស្រស់ស្អាតបានណា!″ ″ឡានតាក់ស៊ីរបស់ប៉ា នឹងកាន់តែទាក់ទាញ បើព្យួរតុក្កតារូបសត្វជាប់នឹងកញ្ចក់ឡាន។″ ″បងហេង ចូលចិត្តផ្កាយ។ ដូច្នេះយើងគួរបិទរូបផ្កាយៗនៅតាមជញ្ជាំងបន្ទប់របស់គាត់!″ ″ចំណែកម៉ាក់ ចូលចិត្តព្រះអាទិត្យ។ ប៉ុន្ដែខ្ញុំមិនយល់ថា ហេតុអ្វីគាត់មិនចូលចិត្តរង្វង់មូលធំពណ៌លឿងដែលខ្ញុំគូរលើពិដាននោះទេ។″



លោកយាយ ដកដង្ហើមបន្តិច រួចនិយាយ "ចៅនិយាយបែបនេះធ្វើឲ្យយាយនឹកដល់ មាលា កូនស្រីរបស់មិត្តភក្តិយាយម្នាក់។ ឥឡូវនាង គឺជាអ្នករចនាផ្ទៃខាងក្នុងនៃបន្ទប់ ឬអគារ ។" "តើគាត់ធ្វើការជាអ្នកតុបតែងផ្ទះឲ្យគេមែនទេលោកយាយ?" "មិនអីចឹងទាំងស្រុងទេ។ មាលា ជាអ្នកសម្រេចថាកន្លែងណាត្រូវរៀបមានជញ្ជាំង ដាក់បង្អួច និងតាំងគ្រឿងសង្ហារិមក្នុងអគារដើម្បីទាក់ទាញ និងមានផាសុកភាព ពេលមនុស្សដើរចូលទៅកន្លែងនោះ។ ក្រៅពីនេះ មាលា ក៏ជាអ្នកសម្រេចថាត្រូវតុបតែងបន្ទប់របៀបណាផងដែរ។ ទាំងនេះសុទ្ធតែជាកិច្ចការរបស់អ្នករចនាលម្អផ្ទៃខាងក្នុង។" អក្ខរា ក៏លាន់មាត់ថា "អូ! ស្តាប់ទៅអស្ចារ្យមែនទែន។ ខ្ញុំក៏ចង់ធ្វើដូចគាត់ដែរ។" លោកយាយ បន្តថា "ចាំ

មើលក្រែង មាលា អាចឆ្លៀតមកលេងយាយបាន។”



នៅចុងសប្ដាហ៍ មាលា បានមកលេងលោកយាយ។ ភ្លាមនោះ អក្ខរា ចាប់ផ្ដើមបង្ហាញពីផែនការរបស់នាងទៅ មាលា។ ”មីង! ដំបូងយើងនឹងរុំអ្វីៗដោយបូពណ៌លឿង ព្រោះវាជាពណ៌ដែលល្អជាងគេក្នុងលោក។ បន្ទាប់មកយើងនឹងចងកណ្ដឹងពណ៌ក្រហមរួច...” មកដល់ត្រឹមនេះ មាលា ក៏លាន់មាត់ ”អូហូ! ស្ដាប់ទៅពិតជាគំនិតថ្មីមែន។ តើក្មួយចង់តុបតែងអ្វីឡើងវិញ?” អក្ខរា លាន់មាត់ ”ផ្ទះបាយរបស់ម៉ាក់។ បន្ទាប់មកមីង និងខ្ញុំ អាចជួយគ្នារចនាបន្ទប់ទទួលភ្ញៀវឡើងវិញ។ គំនិតខ្ញុំល្អបំផុតហើយ!
”



មាលា ស្តាប់រាល់គំនិតរបស់ អក្ខរា។ មាលា និយាយថា ”ក្មួយពិតជាមានគំនិតឆ្នៃប្រឌិតមែន! មីងពេញចិត្តណាស់។ នេះជាជំនាញដ៏សំខាន់បំផុតសម្រាប់អ្នករចនាលម្អផ្ទៃខាងក្នុង! ” ” ប៉ុន្តែរឿងដំបូងដែលអ្នករចនាលម្អផ្ទៃខាងក្នុងត្រូវដឹងសម្រាប់ការងាររបស់ខ្លួនគឺ តើយើងរចនាឲ្យនរណា ហើយពួកគេចង់បានអ្វី?



អក្ខរា ទម្លាក់ខ្លួនលើកៅអី រួចនិយាយ ”តែម៉ាក់ មិនយល់ព្រម
ទេ ព្រោះគាត់មិនចូលចិត្តគំនិតរបស់ខ្ញុំ។” ”មីងជឿថា ម៉ាក់ក្មួយ
ច្បាស់ជាពេញចិត្តគំនិតរបស់ក្មួយ។ គ្រាន់តែនេះមិនមែនជាអ្វី
ដែលគាត់ត្រូវការចាំបាច់ប៉ុណ្ណោះ។”



លោកយាយក៏លើកឡើងថា "ចៅដឹងទេ យាយកំពុងគិតថា បន្ទប់យើងក៏ត្រូវការកែលម្អខ្លះដែរ។ តើចៅទាំងពីរមានស្គាល់ អ្នករចនាបន្ទប់ ណាទេ?" អក្ខរា បើកភ្នែកធំៗ រួចនិយាយថា " តើយាយអាចឲ្យមីង មាលា និងខ្ញុំ រចនាបន្ទប់យើងឡើងវិញ បានទេ?" លោកយាយ ញញឹម រួចតប "យាយចង់បានអ្នក រចនា ដ៏ល្អបំផុតសម្រាប់បន្ទប់យើង!"



អក្ខរា ក៏នាំផ្លូវទៅកាន់បន្ទប់គេង និងត្រៀមកត់ត្រា។ អក្ខរា សួរថា ”តើលោកយាយ ចង់រៀបចំបន្ទប់នេះយ៉ាងម៉េចវិញ? ” លោកយាយ ក្រឡេកឃើញសៀវភៅរាយប៉ាយលើឥដ្ឋ រួច និយាយថា ”យាយចង់ឲ្យបន្ទប់នេះភ្លឺជាងមុន ហើយមាន សណ្ដាប់ធ្នាប់ជាងនេះ។”



អក្ខរា លាន់មាន់ថា ”យើងអាចឲ្យប៉ាពង្រីកបង្អួចឲ្យធំជាងមុន រួចទិញធ្នើរដាក់សៀវភៅមួយ!” លោកយាយ ក្រឡេកឃើញកូនជ្រូកសន្សំលុយរបស់គាត់ ហើយនិយាយថា ”គំនិតល្អ! ប៉ុន្តែយើងមិនអាចចំណាយច្រើនដល់ម្លឹងទេចៅ!” មាលា ក៏លើកឡើងថា ”ក្មួយអាចសាក ពិភាក្សាជាមួយអ្នកជុំវិញខ្លួន ហើយសង្កេតមើលបរិយាកាសជុំវិញខ្លួនដើម្បីបានជាគំនិត។ ក្មួយនឹងភ្ញាក់ផ្អើលនូវអ្វីដែលក្មួយអាចធ្វើបានដោយមិនចាំបាច់ទិញរបស់ថ្មីៗច្រើន។”



ល្ងាចឡើង អក្ខរា ចាប់ផ្តើមសញ្ជឹងគិត។ នាងរកបានធុងឈើ និងក្រណាត់ចាស់ៗមួយចំនួន។ ”ប៉ា! តើកូនអាចប្រើរបស់ទាំងនេះដើម្បីតុបតែងបន្ទប់យើងបានទេ?” ប៉ារបស់អក្ខរាក៏តបថា ”បានកូន! ប៉ានឹងយកធុងឈើទាំងនោះទៅច្នៃធ្វើជាធ្នើរដាក់សៀវភៅ ហើយកូនអាចជួយលាបពណ៌។”



ប៉ុន្តែ អក្ខរា មិនដឹងថា ត្រូវធ្វើយ៉ាងណាឲ្យបន្ទប់ភ្លឺជាងមុននោះ
ទេ។ នាងក៏សុំយោបល់ពីម៉ាក់នាង។ ”យើងមានកញ្ចក់ចាស់
មួយក្នុងទូខោអាវ។ ម៉ាក់យល់ថា កញ្ចក់អាចជួយបន្ថែមពន្លឺបាន
ហើយធ្វើឲ្យបន្ទប់មើលទៅធំជាងមុន។”



ពីរបីថ្ងៃក្រោយមក អក្ខរា អង្គុយជជែកគ្នាជាមួយ មាលា អំពីអ្វីដែលនាងរកបាន។ មាលា និយាយថា ”កញ្ចក់ និងធុងឈើ ជាការចាប់ផ្ដើមដ៏ល្អ។ ក្រៅពីនេះ ក្មួយអាចរំកិលគ្រែឲ្យឆ្ងាយពីបង្អួចបន្តិច ដើម្បីឲ្យពន្លឺចាំងចូលទៅលើផ្ទៃឥដ្ឋ។” អក្ខរា តបថា ”បន្ទប់យើង ច្បាស់ជាស្រស់ស្អាតជាងមុនមិនខាន។”



មាលា និយាយថា "អស្ចារ្យ! ចំណុចសំខាន់សម្រាប់អ្នករចនា គឺត្រូវគិតពីអារម្មណ៍អ្នករស់នៅក្នុងបន្ទប់ថ្មីនោះ។" "ជំហានបន្ទាប់គឺត្រូវបង្ហាញភ្ញៀវពីគំនិត ដែលក្មួយចង់ធ្វើ។ ដូច្នេះគាត់អាចសម្រេចចិត្តលើការងារនេះ មុនពេលក្មួយអនុវត្ត។"



អក្ខរា សួរថា "តើខ្ញុំអាចគូរប្លង់ដើម្បីបង្ហាញលោកយាយពីគំនិតរៀបចំរបស់ខ្ញុំបានទេ?" "នេះជាអ្វីដែលអ្នកជំនាញខាងរចនាលម្អត្រូវធ្វើ។ យើងគូសផែនទី និងគំនូសព្រាង ដែលហៅថាប្លង់។"



អក្ខរា បង្ហាញលោកយាយពីប្លង់របស់នាង ព្រមទាំងពន្យល់ពីការរំកិលគ្រែដើម្បីបានចន្លោះកាន់តែធំ។ ”យាយពេញចិត្តណាស់ចៅ! ចៅឆ្លាតណាស់ដែលចេះយកកំណាត់ឈើ និងកញ្ចក់មកច្នៃប្រើឡើងវិញ។ ធ្វើបន្តទៀតទៅចៅ!”



អក្ខរា និង មាលា ធ្វើកិច្ចការរៀងៗខ្លួន។





ពេលកិច្ចការបញ្ចប់រួចរាល់ អក្ខរា និង មាលា ក៏នាំលោកយាយ
មកមើលបន្ទប់។ អក្ខរា ស្រែកថា "លោកយាយ បើកភ្នែកឡើង!"





លោកយាយនាង និយាយថា ”អស្ចារ្យណាស់! បន្ទប់នេះភ្លឺ និង មានសណ្តាប់ធ្នាប់ជាងមុន។ យាយចង់បានបែបនេះ។ ប៉ុន្តែវា ដូចជាខ្វះអ្វីម្យ៉ាង។ ” អក្ខរា ភាំងបន្តិច។



លោកយាយក៏ទាញយកកន្សែងបង់កពណ៌លឿងមួយពីក្នុងទូខោអាវ រួចព្យួរវាជុំវិញបង្អួច។ អក្ខរា ឱបលោកយាយ រួចនិយាយថា ”ឥឡូវ បន្ទប់យើងល្អឥតខ្ចោះតែម្ដង!” មាលា ក៏ពោលថា ”យើងសហការគ្នាបានល្អណាស់។ អបអរសាទរដែលក្មួយអាចបញ្ចប់ការងារដំបូងរបស់ក្មួយបាន។”



ម៉ាក់របស់អក្ខរា ឈប់មួយស្របក់ រួចលាន់មាត់សរសើរថា ”បន្ទប់នេះស្អាតណាស់!” ”អក្ខរា! តើគម្រោងបន្ទាប់ កូនចង់ធ្វើអ្វីទៀត?”



Generously supported by Smart Axiata

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.

booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*ក្តីស្រមៃរបស់អ្នករចនាលម្អម្នាក់ (A Designer’s Dream)*, Author: The Asia Foundation - Let’s Read. Illustrator: Youn Sokhoeut. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

CC BY NC

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/